# ធនាគារ ព្រីនស៍ ម.ក

## បញ្ញត្តិនិងលក្ខខណ្ឌសម្រាប់កម្មវិធីលើកទឹកចិត្តលើការដាក់ប្រាក់បញ្ញើមានកាលកំណត់ជាប្រាក់រៀល

ធនាគារ ព្រីនស៍ ម.ក ("**ធនាគារ ព្រីនស៍**") កំពុងដាក់ដំណើរការកម្មវិធីលើកទឹកចិត្តលើការដាក់ប្រាក់បញ្ញើមានកាលកំណត់ជាប្រាក់រៀល ដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌ ដែលបានចែងនៅទីនេះ ("**កម្មវិធីលើកទឹកចិត្ត**")។ តាមរយៈការចូលរួមកម្មវិធីលើកទឹកចិត្តនេះ អ្នកចូលរួមយល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌដូចខាងក្រោម ព្រមទាំងបញ្ញត្តិ និងលក្ខខណ្ឌទូទៅ បញ្ញត្តិនិងលក្ខខណ្ឌជាក់លាក់សម្រាប់គណនីប្រាក់បញ្ញើមានកាលកំណត់ និងបញ្ញត្តិ និងលក្ខខណ្ឌដែលពាក់ព័ន្ធដទៃទៀត៖

១. រាល់អតិថិជនជារូបវន្តបុគ្គល នីតិបុគ្គល ឬអតិថិជនសេវាធនាគារអាទិភាព ("**អ្នកចូលរួម**") អាចចូលរួមក្នុងកម្មវិធីលើកទឹកចិត្តនេះ ដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌនេះ។

២. អ្នកចូលរួមដែលបានបើកគណនីបញ្ញើមានកាលកំណត់ថ្មីជាប្រាក់រៀល សម្រាប់រយៈពេលបញ្ញើជាក់លាក់ណាមួយនៅតាមសាខាប្រតិបត្តិការណាមួយរបស់ ធនាគារ ព្រីនស៍ នឹងទទួលបានការផ្តល់ជូននូវអត្រាការប្រាក់ពិសេស ដោយអនុលោមតាមលក្ខខណ្ឌដូចមានចែងខាងក្រោម៖

| ផលិតផល | រយៈពេល | អត្រាការប្រាក់ផ្តល់ជូន | | |
|---|---|---|---|---|
| | | អត្រាពិសេស | អត្រាពិសេសនៅពេលបើកជាកញ្ចប់ជាមួយគណនីសន្សំឆ្លាតណាមួយ | អត្រាពិសេសនៅពេលបើកជាកញ្ចប់ជាមួយគណនីទ្វេទ្រព្យ |
| បើកគណនីបញ្ញើមានកាលកំណត់ថ្មីជាប្រាក់រៀល តាមរយៈសាខាប្រតិបត្តិការ | ៣ ខែ | ៣,៥០ % ក្នុងមួយឆ្នាំ | ៤,២៥ % ក្នុងមួយឆ្នាំ | ៤,៤០ % ក្នុងមួយឆ្នាំ |
| | ៤ ខែ | ៣,៧៥ % ក្នុងមួយឆ្នាំ | ៤,៥០ % ក្នុងមួយឆ្នាំ | ៤,៦៥ % ក្នុងមួយឆ្នាំ |
| | ៥ ខែ | ៤,០០ % ក្នុងមួយឆ្នាំ | ៤,៧៥ % ក្នុងមួយឆ្នាំ | ៤,៩០ % ក្នុងមួយឆ្នាំ |
| | ៦ ខែ | ៤,៥០ % ក្នុងមួយឆ្នាំ | ៤,៨៥ % ក្នុងមួយឆ្នាំ | ៥,០០ % ក្នុងមួយឆ្នាំ |
| | ៧ ខែ | ៤,៧៥ % ក្នុងមួយឆ្នាំ | ៥,០០ % ក្នុងមួយឆ្នាំ | ៥,១៥ % ក្នុងមួយឆ្នាំ |

**លក្ខខណ្ឌ៖**

- ការផ្តល់ជូននេះ គឺសម្រាប់តែគណនីបញ្ញើមានកាលកំណត់ជាប្រាក់រៀល ដែលត្រូវបានបើក ក្នុងរយៈពេលនៃកម្មវិធីលើកទឹកចិត្ត ដែលគិតចាប់ពី **ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤**។ រយៈពេលនៃកម្មវិធីលើកទឹកចិត្តនេះ អាចត្រូវបានកែប្រែដោយមានការជូនដំណឹងពីធនាគារ ព្រីនស៍។
- អតិថិជនជារូបវន្តបុគ្គលត្រូវដាក់ទឹកប្រាក់បញ្ញើអប្បបរមាចំនួន ៤.០០០.០០០ រៀល ហើយអតិថិជនជានីតិបុគ្គល ឬអតិថិជនសេវាធនាគារអាទិភាព ត្រូវដាក់ទឹកប្រាក់បញ្ញើអប្បបរមាចំនួន ៤០.០០០.០០០ រៀល។
- ទឹកប្រាក់បញ្ញើត្រូវកម្រិតត្រឹមចំនួនអតិបរមា ៤.០០០.០០០.០០០ រៀល សម្រាប់អ្នកចូលរួមម្នាក់ៗ និងសម្រាប់មួយគណនីបញ្ញើមានកាលកំណត់។

- នៅពេលបើកគណនីបញ្ញើមានកាលកំណត់ជាប្រាក់រៀល តម្រូវឲ្យកំណត់យកលក្ខខណ្ឌបន្តដាក់បញ្ញើឡើងវិញដោយស្វ័យប្រវត្តិ និងទទួលការប្រាក់នៅចុងគ្រា។ នៅពេលដែលគណនីបញ្ញើមានកាលកំណត់ជាប្រាក់រៀល ត្រូវបានបន្តដាក់បញ្ញើឡើងវិញដោយស្វ័យប្រវត្តិ នោះអត្រាការប្រាក់ស្តង់ដារត្រូវអនុវត្ត។ ចំពោះគណនីបញ្ញើមានកាលកំណត់ជាប្រាក់រៀលសម្រាប់រយៈពេល៤ខែ ឬ៥ខែ ដែលត្រូវបានបន្តដាក់បញ្ញើឡើងវិញដោយស្វ័យប្រវត្តិ នឹងទទួលបានអត្រាការប្រាក់នៃគណនីបញ្ញើមានកាលកំណត់ជាប្រាក់រៀលសម្រាប់រយៈពេល៦ខែ។ ចំពោះគណនីបញ្ញើមានកាលកំណត់ជាប្រាក់រៀលសម្រាប់រយៈពេល៧ខែ ដែលត្រូវបានបន្តដាក់បញ្ញើឡើងវិញដោយស្វ័យប្រវត្តិ នឹងទទួលបានអត្រាការប្រាក់នៃគណនីបញ្ញើមានកាលកំណត់ជាប្រាក់រៀលសម្រាប់រយៈពេល៩ខែ។
- អ្នកចូលរួមនឹងទទួលបានអត្រាការប្រាក់កាន់តែពិសេស ប្រសិនបើបើកគណនីបញ្ញើមានកាលកំណត់ជាប្រាក់រៀលរួមគ្នាជាមួយនឹងគណនីសន្សំឆ្លាតវៃ គណនីសន្សំឆ្លាតបៀលជី ឬគណនីទ្វេទ្រព្យ។
- អ្នកចូលរួមដែលទទួលបានអត្ថប្រយោជន៍ដែលមានផ្តល់ជូននៅក្រោមកម្មវិធីនេះ នឹងមិនទទួលបានអត្ថប្រយោជន៍ឬការផ្តល់ជូននៅក្រោមកម្មវិធីលើកទឹកចិត្ត ឬគម្រោងអត្ថប្រយោជន៍ដទៃទៀតទន្ទឹមគ្នាឡើយ។
- អ្នកចូលរួមនឹងទទួលបានអត្រាការប្រាក់នៃគណនីសន្សំធម្មតាប៉ុណ្ណោះដែលកំណត់ដោយធនាគារ ព្រីនស៍ ប្រសិនបើបិទគណនីបញ្ញើមានកាលកំណត់ជាប្រាក់រៀលមុនពាក់កណ្តាលរយៈពេលដាក់បញ្ញើ និងទទួលបានអត្រាការប្រាក់ពាក់កណ្តាលនៃអត្រាការប្រាក់ផ្តល់ជូនតាមរយៈកម្មវិធីនេះ ប្រសិនបើបិទគណនីបញ្ញើមានកាលកំណត់ជាប្រាក់រៀលក្រោយពាក់កណ្តាលរយៈពេលដាក់បញ្ញើ។

៣. ក្នុងករណីមានការឆបោក ឬក្លែងបន្លំដែលប្រព្រឹត្តដោយ ឬមានពាក់ព័ន្ធនឹងអ្នកចូលរួមទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ អ្នកចូលរួមរូបនោះនឹងបាត់បង់សិទ្ធិចូលរួមកម្មវិធីលើកទឹកចិត្តនេះ ដោយរួមទាំងអត្ថប្រយោជន៍ផ្សេងៗដែលខ្លួនទទួលបាន។ អ្នកចូលរួមត្រូវប្រគល់ជូនធនាគារ ព្រីនស៍ វិញ នូវរាល់អត្ថប្រយោជន៍ដែលខ្លួនបានទទួលពី ធនាគារ ព្រីនស៍ តាមរយៈកម្មវិធីលើកទឹកចិត្តនេះ (ប្រសិនបើមាន) និងត្រូវសងសំណងការខូចខាតផ្សេងៗទៅតាមបញ្ញត្តិច្បាប់ជាធរមាន។

៤. ការរក្សាសិទ្ធិ ការរួចផុត និងការកម្រិតនៃការទទួលខុសត្រូវ

ក. អ្នកចូលរួម យល់ព្រមថា ធនាគារ ព្រីនស៍ រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល ឬបុគ្គលិករបស់ ធនាគារ ព្រីនស៍ មិនត្រូវទទួលខុសត្រូវលើ រាល់ការខូចខាតណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាពិសេស ឬដោយចៃដន្យ ដែលកើតឡើង ទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះឡើយ។

ខ. អ្នកចូលរួម យល់ព្រមដោយមិនអាចដកហូតវិញបានថា អ្នកចូលរួមយល់ព្រមសងសំណង និងធានាថា ធនាគារ ព្រីនស៍ នឹងទទួលបានសំណងគ្រប់ពេលណាមួយ លើរាល់ការបាត់បង់ ការខូចខាត កម្រៃសេវា កម្រៃសេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ និងរាល់ផលវិបាកដែលកើតឡើងលើធនាគារ ព្រីនស៍ ឬបានទទួលរងដោយ ធនាគារ ព្រីនស៍ ចំពោះការទាមទារ ឬបណ្តឹងណាមួយដែលធ្វើឡើងដោយអ្នកចូលរួម ឬភាគីទីបី ដែលកើតឡើង ឬទាក់ទងនឹងបញ្ញត្តិដែលមានចែងក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

៥. ធនាគារ ព្រីនស៍ រក្សាសិទ្ធិគ្រប់យ៉ាង ក្នុងការធ្វើវិសោធនកម្មលើបញ្ញត្តិនិងលក្ខខណ្ឌនេះ ពន្យាពេលបន្ថែមរយៈពេល ឬលុបចោលកម្មវិធីលើកចិត្តនេះ និង/ឬការផ្តល់ជូន នៅពេលណាមួយក្នុងរយៈពេលកម្ម

វិធីលើកទឹកចិត្ត ដោយមិនមានការទទួលខុសត្រូវ តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ ធនាគារ ព្រីនស៍ ដោយគ្រាន់តែផ្តល់ការជូនដំណឹងពីការផ្លាស់ប្តូរ នៅលើគេហទំព័រផ្លូវការ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងទៀតរបស់ ធនាគារ ព្រីនស៍។

៦. បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតឡើង ឬទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ នឹងត្រូវបានដោះស្រាយ ដោយអនុលោមតាមគោលនយោបាយដោះស្រាយបណ្តឹងអតិថិជនរបស់ធនាគារ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។